# Forceps

## ដង្កាប់



ធ្មេញថ្គមធំផ្នែកលើមានឬស៣បែកចេញពីគ្នា។

ឬសធំ១ចាក់ចូលទៅក្រអូបមាត់ “ នៅពាក់កណ្តាលនៃមាត់ “ ។

ឬស២ ទៀតងាកទៅខាង Buccal “ឬសធ្មេញនៅជាប់ថ្ពាល់។

ដង្កាប់ទាំង២ ត្រូវបានផលិតឡើង ដើម្បីអោយស៊ីគ្នា ទៅនឹងឬសរបស់ធ្មេញ។

ដង្កាប់ធ្មេញថ្គាមស្តាំខាងលើមានចំពុះមូលនៅខាងស្តាំដង្កាប់។

ដង្កាប់ធ្មេញថ្គាមខាងឆ្វេងលើមានចំពុះស្រួចនៅខាងស្តាំ

ដើម្បីងាយចាប់ចន្លោះឬសធ្មេញផ្នែក Buccal ទាំងពីរ ដែលនៅជាប់ថ្ពាល់។








សំរាប់ធ្មេញថ្គាមតូចខាងលើទាំង ចង្កូម រឺ ពួកធ្មេញមុខ មុខដង្កាប់ភាគច្រើន ត្រង់រឺ កោងបន្តិចបន្តួច ។

ដង្កាប់មាន៤ប្រភេទ គឺ

-Upper straight forceps

-Upper universal forceps
-Upper fine forceps
-Root forceps





ដង្កាប់សំរាប់ថ្គាមក្រោម មានលក្ខណះងាយស្រួលក្នុងការ ចំណាំ  ដោយសារតែចំពុះចាប់ របស់វាកោងចុះក្រោម  ដែលកែងជាមួយនឹងដងចាប់ ។





ដង្កាប់សំរាប់ធ្មេញថ្គាមធំខាងក្រោមមាន ចុងស្រួចពីរនៅផ្នែកចំពុះ ដែលស៊ីគ្នាទៅនឹង ចន្លោះឬសទាំងពីរ របស់ធ្មេញ ។







ដង្កាប់ ដែលមានរាងជា ស្នែងក្របី រឺ ចំពុះសត្វឥន្ទ្រី
មានចំពុះស្រួច២ ដែលស៊ីគ្នាទៅនឹងចន្លោះ
ឫសធ្មេញថ្គាមក្រោម ទាំងពីរ ។
ដង្កាប់នេះអាចប្រើច្រើននៅពេលដែល Crown
ធ្មេញខូចយ៉ាងធ្ងន់ធ្ងរ ។ ភាគច្រើនវា
បំបែកឫសធ្មេញទាំងពីរចេញពីគ្នា
នៅពេលដែលយើងចាប់សង្កត់វាអោយខ្លាំង ។
បន្ទាប់មក យើងអាចប្រើ elevator
គាស់យកឫសធ្មេញ ចេញម្តងមួយ ។





Universal forceps សំរាប់ធ្មេញថ្គាមតូច រឺ ចង្កូមខាងក្រោម

Fine forceps សំរាប់ដកធ្មេញមុខខាងក្រោម និង ឫស





ដង្កាប់សំរាប់ដកធ្មេញកូនក្មេង ស្រដៀងនឹងដង្កាប់ដកធ្មេញមនុស្សធំដែរ
ប៉ុន្តែវាមានទំហំតូចជាងដង្កាប់មនុស្សធំ ។

ដង្កាប់ សំរាប់ដកធ្មេញកុមារខាងក្រោមមាន២ប្រភេទ។
ចំពុះដែលស្រួចនៅខាងចុង ត្រូវបានប្រើសំរាប់ដកធ្មេញថ្គាម និង ចំពុះដែល
មានមុខមូលនៅខាងចុង ត្រូវបានប្រើសំរាប់ដក ចង្កូម និង ធ្មេញមុខ។











ដង្កាប់ សំរាប់ដកធ្មេញទឹកដោះ ចង្កូម និង ធ្មេញមុខផ្នែកខាងលើ មានមុខត្រង់
ឯសំរាប់ដកធ្មេញថ្គាមទឹកដោះផ្នែកខាងលើ មានមុខកោង ។